**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខៈ ០៤០/២២ អអរ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង"

ព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ឡុង ឈុនឡៃ ប្រធានក្រុមប្រឹក្សាខេត្ត**
- **ឯកឧត្តម ស៊ុន សុវណ្ណារិទ្ធ អភិបាល នៃគណៈអភិបាលខេត្ត**
- **លោក ម៉ឹង វិសាលសុខ មេឃុំក្តុលសែនជ័យ ស្រុកទឹកផុស**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្រ្តកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្តីផ្តើម

ខេត្តកំពង់ឆ្នាំង ចែកចេញជា ៧ស្រុក ១ក្រុង មាន ៧០ឃុំសង្កាត់ ចែក-ជា ៥៦៩ភូមិ មានប្រជាពលរដ្ឋ ចំនួន ១៣៦ ៩៥៨ គ្រួសារ ប្រជាពលរដ្ឋសរុប ៥៦៩ ៥៦៤ នាក់ ស្រី ២៩៤ ៤៦៣ នាក់។ សេដ្ឋកិច្ចឆ្នាំ២០២០ មានទំហំ ៨៥៩.៤លានដុល្លារ ដែលចូលរួមពីវិស័យកសិកម្មមានចំនួន ៥៧,២%, ឧស្សាហកម្ម សិប្បកម្ម និងសំណង់មានចំនួន ២៥.៤% និងចំណូលពីវិស័យសេវាកម្ម ១៧,៤% ចំណែកអត្រាភាពក្រីក្របានថយចុះពី ២០,៨២ % នៅឆ្នាំ២០១៤ មកនៅត្រឹម ១៨,១៧% នៅឆ្នាំ២០២០ និងនៅឆ្នាំ ២០២១ មានចំនួន ១៨,៨៧% ដោយសារវិបត្តិ នៃជំងឺកូវីដ-១៩។

## II. វឌ្ឍនភាពការងារសំខាន់ៗ

### ❖ ក្រុមប្រឹក្សាខេត្ត

- ក្រុមប្រឹក្សាខេត្តមាន គណៈកម្មាធិការ ចំនួន៣ ដើម្បីអនុវត្តនូវតួនាទីភារកិច្ចការងាររួមមាន៖ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការលទ្ធកម្ម និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- បានរៀបចំកិច្ចប្រជុំសម្រាប់ត្រួតពិនិត្យ និងពិភាក្សាការងារ ព្រមទាំងបានរៀបចំកិច្ចប្រជុំសម្ងាត់ ដើម្បីវាយតម្លៃការតែងតាំង ផ្លាស់ប្តូរមុខតំណែងមន្ត្រីស្របតាមលិខិតបទដ្ឋានគតិយុត្ត ប្រកបដោយតម្លាភាព និងយុត្តិធម៌
- ចូលរួមរាល់សកម្មភាពអភិវឌ្ឍន៍ សកម្មភាពសង្គម និងសកម្មភាពផ្នែកសាសនា ជាមួយថ្នាក់ដឹកនាំខេត្ត និងបានចែករំលែកព័ត៌មានដល់សមាជិកនានាក្នុងជួរក្រុមប្រឹក្សា
- បានរៀចំបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើស ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ ថ្នាក់ខេត្ត ក្រុង ស្រុក
- បានចូលរួមគាំទ្រសកម្មភាព ផអ៣ នៅថ្នាក់ខេត្ត និងនៅមូលដ្ឋាន(ក្រុងស្រុក និងឃុំសង្កាត់)
- ការគាំទ្រការរៀបចំ និងអនុវត្តគម្រោង ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ក្នុងឆ្នាំ២០២១៖ គម្រោងរបស់រដ្ឋបាលខេត្ត មានចំនួន ៩គម្រោង, គម្រោងរបស់ក្រុង ស្រុក ១៧គម្រោង, គម្រោងឃុំសង្កាត់មាន ៥០ គម្រោង
- បានរៀបចំវេទិការផ្សព្វផ្សាយ និងពិគ្រោះយោបល់តាមបណ្តាក្រុង ស្រុក ទាំង៨
- បានចូលរួមក្នុងយុទ្ធនាការចុះពិនិត្យស្រាវជ្រាវ និងដកហូតដីដែលត្រូវបានជនខិលខូចកាប់ទន្រ្ទានកាន់កាប់យកធ្វើជាកម្មសិទ្ធិក្នុងតំបន់៣ នៃភូមិសាស្ត្រជុំវិញបឹងទន្លេសាប។

### ❖ ឃុំក្តុលសែនជ័យ ស្រុកទឹកផុស

វឌ្ឍនភាពសំខាន់ៗ ដែលក្រុមប្រឹក្សាឃុំសម្រេចបានរួមមាន៖

- បានអនុវត្តនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព, រៀបចំសណ្តាប់ធ្នាប់, ការពារសន្តិសុខជូនប្រជាពលរដ្ឋ និងមានការដោះស្រាយ សម្របសម្រួលបណ្តឹងជូនប្រជាពលរដ្ឋ
- បានជួសជុលផ្លូវ ស្ពារប្រឡាយទឹក ប្រព័ន្ធលូរំដោះទឹក និងបានសាងសង់បង្គន់អនាម័យ ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធចែកចាយទឹកស្អាតនៅតាមបណ្តាភូមិ
- បានរៀបចំរមណីយដ្ឋានធម្មជាតិទឹកធ្លាក់ធម្មជាតិស្រែអំពិល ដែលជាគម្រោងថវិកា និងការគាំទ្រពីក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងសប្បុរសជន

- បានពង្រឹងការអនុវត្ត និងបានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចូលរួមគាំទ្រគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព
- បានផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងបានអនុវត្តកម្មវិធីឧបត្ថម្ភសាចើប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ ស្ត្រីមានផ្ទៃពោះ និងកុមារ។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- ជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយដើម្បីបង្ខិតសេវាសាធារណៈឱ្យកៀក នឹងប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍ និងការកសាងកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ឱ្យមានសង្គតិភាព និងការរៀបចំយុទ្ធសាស្ត្រថវិកា ឱ្យសមស្របទៅតម្រូវការក្នុងការអភិវឌ្ឍន៍
- បន្តការគាំទ្រយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងតាមរយៈការិយាល័យប្រជាពលរដ្ឋ
- បន្តជំរុញការអនុវត្តនូវគោលការណ៍រដ្ឋបាលឯកភាព និងគោលនយោបាយភូមិឃុំ មានសុវត្ថិភាព
- បន្តការគាំទ្រយន្តការមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពដល់រដ្ឋបាលខេត្ត ក្រុងស្រុក និង ឃុំ សង្កាត់
- បន្តចូលរួមក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ចូលរួមផ្សព្វផ្សាយអប់រំណែនាំ ប្រជាពលរដ្ឋនៅមូលដ្ឋានតាមសារអប់រំណែនាំរបស់ក្រសួងសុខាភិបាល។

### ❖ ឃុំក្តុលសែនជ័យ ស្រុកទឹកផុស

- ខិតខំលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- បន្តការខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព និងពង្រឹងសុខសណ្តាប់ធ្នាប់សាធារណៈ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- បន្តពង្រឹងការដោះស្រាយវិវាទដីធ្លី និងបញ្ហាផ្សេងៗក្រៅប្រព័ន្ធតុលាការ ដោយភាពត្រឹមត្រូវ និងយុត្តិធម៌
- បង្កើនការគ្រប់គ្រងរួមគ្នា ក្នុងតំបន់ការពារធម្មជាតិ ជាមួយក្រុមឧទ្យានុរក្ស និងសហគមន៍ ក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ នៅក្នុងដែនសមត្ថកិច្ច

- ខិតខំគៀងគរអង្គការដៃគូ អ្នកវិនិយោគ និងសប្បុរសជនជិតឆ្ងាយ ដើម្បីចូលរួមអភិវឌ្ឍន៍ភូមិឃុំឱ្យមានភាពរីកចម្រើន។
- បន្តពង្រឹងពង្រីកតំបន់ទេសចរណ៍ អោយក្លាយជារមណីយដ្ឋានដ៏មានសក្តានុពល ដើម្បីជាផលប្រយោជន៍ ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បន្តចូលរួមសកម្មភាពនានាក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសបន្តអប់រំ និងណែនាំដល់ប្រជាពលរដ្ឋឱ្យអនុវត្តវិធានការ ៣កុំ និង ៣ការពារ។

## IV. ផ្សេងៗ

- នៅក្នុងយុទ្ធនាការដកហូតដីព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបគឺ ប្រជាពលរដ្ឋស្ម័គ្រចិត្តធ្វើលិខិតប្រគល់ដីជូនរដ្ឋសរុបចំនួន ៧ ៥៣១គ្រួសារ លើផ្ទៃដីទំហំ ៣០ ៥៨៩ហិកតា។ ក្នុងយុទ្ធនាការនេះ រដ្ឋបាលខេត្ត បានរុះរើរោងចំនួន ៥៥រោង និងបានដកបង្គោលកំណត់ព្រំដី ២២៣បង្គោល បញ្ចប់តាមផែនការ ១០០% ស្ថិតនៅក្នុងស្រុកកំពង់លែង និងបានដាំកូនឈើក្នុងតំបន់ព្រៃលិចទឹកឡើងវិញចំនួន ២៣ ២៤៤ ដើម និងកប់គ្រាប់ត្នោតនៅតាមព្រំប្រទល់ព្រៃលិចទឹកតំបន់៣បាន ១១ ៣៣៤ គ្រាប់នៅក្នុងភូមិសាស្ត្រស្រុកបរិបូណ៌ និងស្រុកកំពង់លែង។

- នៅក្នុងសន្និសីទសារព័ត៌មាននេះ ទទួលបានសំណួរពីអ្នកសារព័ត៌មាន និងការពន្យល់បកស្រាយពីសំណាក់វាគ្មិនដូចខាងក្រោម៖

១. តើទិន្នផលត្រីសរុបក្នុងខេត្ត មានការកើនឡើង ឬថយចុះ?

- ចំពោះផលត្រីសរុបក្នុងខេត្តគឺទទួលបានចំនួន ៣១,៦០០តោន ក្នុងនោះការនេសាទក្នុងដែននេសាទមានចំនួន ១៨.៥៦៦តោន តាមវាលស្រែ ២,១៩៤តោន និងការនេសាទនៅតាមវារីវប្បកម្មមានចំនួន ៩,៨៤០តោន បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ មានកំណើន ២,៥២០តោន។

២. តើរដ្ឋបាលខេត្ត បានជួយដល់ប្រជាពលរដ្ឋដែលបានជម្លៀសមកពីទឹកយ៉ាងដូចម្តេចខ្លះ?

- ប្រជាពលរដ្ឋដែលបានជម្លៀសមកពីផ្ទៃទឹក គឺប្រកបរបរចិញ្ចឹមត្រីតាមប្រពៃណី ដើម្បីទ្រទ្រង់ជីវភាពរស់នៅ។ រដ្ឋបាលខេត្ត បានសហការជាមួយអ្នកជំនាញបច្ចេកទេស ក្នុងការបណ្តុះបណ្តាលជំនាញ និងផ្តល់បច្ចេកទេសក្នុងការចិញ្ចឹមត្រី និងជំនាញផ្សេងៗទៀតជូនប្រជាពលរដ្ឋព្រមទាំងមានគម្រោងសាងសង់សាលាបណ្តុះបណ្តាលជំនាញផងដែរ៕

ថ្ងៃអង្គារ ៨រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២